**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងមុខងារសាធារណៈ**
លេខ : ៩២៤ មស.ចម

ថ្ងៃ ពុធ ១១កើត ខែ ចេត្រ ឆ្នាំជូត ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ មីនា ឆ្នាំ២០២១

**សូមគោរពជូន**
**សម្តេច ឯកឧត្តម លោកជំទាវ**
**ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី និងប្រធានអង្គភាពគ្រប់ក្រសួង ស្ថាប័ន**

**កម្មវត្ថុ៖** សំណើសុំមេត្តាផ្តល់ជាបន្ទាន់នូវស្ថិតិ ថ្នាក់ដឹកនាំ មន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យា របស់ក្រសួង ស្ថាប័ន ដែលមិនទាន់បានចាក់វ៉ាក់សាំងកូវីដ-១៩ ដោយគិតត្រឹមថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២១។

**យោង៖** ប្រសាសន៍ណែនាំជាបន្ទាន់ដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទសូមគោរពជម្រាបជូន **សម្តេច ឯកឧត្តម លោកជំទាវ** មេត្តាជ្រាបថា ដើម្បី អនុវត្តតាមប្រសាសន៍ណែនាំជាបន្ទាន់ដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ក្រសួងមុខងារសាធារណៈ សូមគោរពស្នើផ្តល់ជាបន្ទាន់នូវស្ថិតិថ្នាក់ដឹកនាំ មន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យារបស់ក្រសួង ស្ថាប័ន និងអង្គភាព ដែលមិនទាន់បានចាក់វ៉ាក់សាំងកូវីដ-១៩ ដោយគិតត្រឹមថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២១ (ដោយមិនរាប់បញ្ចូល កងទ័ព នគរបាល គ្រូពេទ្យ និងគ្រូបង្រៀន)។

អាស្រ័យហេតុនេះ ខ្ញុំបាទសូមស្នើ **សម្តេច ឯកឧត្តម លោកជំទាវ** មេត្តាចាត់ នាយកខុទ្ទកាល័យ ឬ ប្រធានអនុគណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩ របស់ក្រសួង ស្ថាប័ន ស្រង់ស្ថិតិតាមគំរូបញ្ជីដែលភ្ជាប់មក ជាមួយនេះរួចផ្ញើជាបន្ទាន់មកក្រសួងមុខងារសាធារណៈ ឱ្យបានមុនម៉ោង**១៥.០០**នាទីរសៀល ក្នុងថ្ងៃទី**២៤** ខែ**មីនា** ឆ្នាំ **២០២១** នេះ ដើម្បីធ្វើការសរុបគោរពផ្ញើជូន **សម្តេចតេជោនាយករដ្ឋមន្ត្រី** ឲ្យបានទាន់ពេលវេលា។

សូមធ្វើការទំនាក់ទំនងតាមរយៈ Telegram/ទូរស័ព្ទ លោក សោម សាវេត 015 21 44 44 លោក ម៉េង ម៉ង់ទិត 017 89 82 58 និងលោក ណែត វ៉ាន់ស៊ីថា 070 67 64 03។

សូម **សម្តេច ឯកឧត្តម លោកជំទាវ** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ពីខ្ញុំបាទ។

**រដ្ឋមន្ត្រី**

ព្រុំ-សុខា

**ចម្លងជូន៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
  "ដើម្បីគោរពជូនជ្រាប"
- គ្រប់ក្រសួង ស្ថាប័ន និងអង្គភាព
  "ដើម្បីអនុវត្ត"
- ឯកសារ កាលប្បវត្តិ

ផ្លូវវិត្តអង្គតាម៉ិញ ភូមិគោកចំបក់ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ/ទូរសារ : +៨៥៥-២៣-៨៦៦៥០១/+៨៥៥-២៣-៨៦៦៥០៥ | គេហទំព័រ : http://www.mcs.gov.kh

# បញ្ជីមន្ត្រីរាជការថ្នាក់ជាតិដែលមិនទាន់បានទទួលវ៉ាក់សាំងបង្ការ កូវីដ-១៩

| លេខរៀង | ក្រសួង-ស្ថាប័ន | ចំនួនមន្ត្រី | | ចំនួនមន្ត្រីដែលបានចាក់រួចហើយ | ចំនួនមន្ត្រីដែលមិនទាន់បានចាក់ | ផ្សេងៗ |
|---|---|---|---|---|---|---|
| | | មន្ត្រីក្របខ័ណ្ឌ | មន្ត្រីកិច្ចសន្យា | | | |
| ១ | | | | | | |
| ២ | | | | | | |
| ៣ | | | | | | |